INTERNATIONAL RIVERS
people • water • life

សម្ព័ន្ធទន្លេកម្ពុជា
Rivers Coalition in Cambodia

*សេចក្ដីប្រកាសព័ត៌មានសម្រាប់ផ្សព្វផ្សាយបន្ទាន់ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៨*

# របាយការណ៍ថ្មីជំរុញអោយមានការធ្វើផែនការថាមពលដែលប្រសើរនៅក្នុងប្រទេសកម្ពុជា  មុនពេលដែលទំនប់វារីអគ្គិសនីទាំងឡាយត្រូវបានអភិវឌ្ឍន៍

វិនិយោគចិនលើវិស័យវារីអគ្គិសនីកម្ពុជា កំពុងគម្រាមកំហែងប្រព័ន្ធអេកូឡូស៊ីដ៏មានតម្លៃបំផុតមួយចំនួនរបស់ប្រទេស និង ជីវភាពរស់នៅរបស់ប្រជាជនរាប់ពាន់នាក់ យោងតាមរបាយការណ៍ស្រាវជ្រាវថ្មីមួយដែលបានផ្សព្វផ្សាយនៅថ្ងៃនេះ។ របាយការណ៍ស្រាវជ្រាវនេះ ដែលត្រូវបានរៀបចំដោយអង្គការទន្លេអន្តរជាតិ (International Rivers) និង សម្ព័ន្ធទន្លេកម្ពុជា (Rivers Coalition in Cambodia) គូសបញ្ជាក់នូវកំណើនចំណាប់អារម្មណ៍លើកិច្ចអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីធំៗដោយអ្នកធ្វើសេចក្ដីសម្រេចចិត្តកម្ពុជាដែលភាគច្រើនត្រូវបានជួយឧបត្ថម្ភគាំទ្រដោយក្រុមហ៊ុនអភិវឌ្ឍនិងហិរញ្ញិកចិន។

កាលពីខែ មេសា ឆ្នាំ ២០០៦ ប្រទេសចិនបានប្រកាសផ្ដល់កញ្ចប់ជំនួយជាទឹកប្រាក់ចំនួន ៦០០ លានដុល្លារអាមេរិកជូនដល់ប្រទេសកម្ពុជា ដែលក្នុងនោះចំនួននៃជំនួយនេះជិតពាក់កណ្ដាលបានផ្ដល់ហិរញ្ញប្បទានលើទំនប់កំចាយ ដែលគឺជាគម្រោងវារីអគ្គិសនីក្នុងស្រុកដ៏ធំទីមួយរបស់ប្រទេសកម្ពុជា។ គម្រោងនេះ ដែលកំពុងត្រូវបានសាងសង់ដោយក្រុមហ៊ុនអភិវឌ្ឍវារីអគ្គិសនីធំបំផុតរបស់ប្រទេសចិន ពោលគឺ សាជីវកម្មស៊ីណូហ៊ីដ្រូ (Sinohydro Corporation) គឺមានទីតាំងទាំងស្រុងនៅក្នុងឧទ្យានជាតិបូកគោ ហើយនឹងជន់លិចព្រៃឈើការពារចំនួន ២.000 ហិកតា។ គម្រោងវារីអគ្គិសនីដ៏ធំទីពីរមួយទៀតត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០៧ ហើយទំនប់ធំៗចំនួនប្រាំមួយថែមទៀតត្រូវបានគេដឹងថាកំពុងត្រូវបានធ្វើការសិក្សាលទ្ធភាព ដែលភាគច្រើនត្រូវបានធ្វើដោយក្រុមហ៊ុនចិន។ គម្រោងចំនួនបួននៃគម្រោងទាំងនេះមានទីតាំងនៅជិតឬនៅក្នុងតំបន់ព្រៃឈើការពារនៃភាគកណ្ដាលជួរភ្នំក្រវាញនៅភូមិភាគនិរតីនៃប្រទេសកម្ពុជា។ លើសពីនេះទៀត វិនិយោគិនចិនកំពុងស្វះស្វែងសាងសង់ទំនប់សំបូរលើទន្លេមេគង្គ ហើយប្រសិនបើទំនប់នេះត្រូវបានស្ថាបនា វាមុខជាខ្ទប់ផ្លូវធ្វើដំណើរសំខាន់ៗរបស់ត្រី និងអាចកាត់បន្ថយចំណូលរបស់អ្នកនេសាទចិញ្ចឹមជីវិត និងអ្នកនេសាទពាណិជ្ជកម្មរាប់ម៉ឺននាក់។ ទំនប់សំបូរ ក៏គម្រាមកំហែងផងដែរដល់ជម្រកត្រីផ្សោតដែលជិតដាច់ពូជ ហើយដែលនៅជុំវិញនោះវិស័យទេសចរណ៍មូលដ្ឋានក៏មានការរីកចម្រើនដែរ។

លោក **ខាល មីឌ្ឌលតុន** (Carl Middleton) អ្នកសម្របសម្រួលកម្មវិធីទន្លេមេគង្គនៃអង្គការទន្លេអន្តរជាតិ (International Rivers) បានមានប្រសាសន៍ថា "ទន្លេហូរដោយសេរី និង ធនធានធម្មជាតិដ៏សម្បូរបែបនៃប្រទេសកម្ពុជា គឺជាភោគទ្រព្យមិនអាចកាត់ថ្លៃបាន ដែលសុខភាពនៃភោគទ្រព្យទាំងនេះគឺមានសារៈសំខាន់ជាអាយុជីវិតចំពោះសុខមាលភាពរបស់ប្រជាជនជនបទកម្ពុជា"។ លោកបានបន្ថែមទៀតថា "កិច្ចអភិវឌ្ឍន៍វារីអគ្គិសនីដែលគិតគូរមិនបានល្អ អាចធ្វើឱ្យខូចខាតធនធានទាំងនេះដែលមិនអាចត្រឡប់ក្រោយវិញបាន និង ធ្វើឱ្យខូចខាតដល់កិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។"

ការសម្រេចបាននូវអគ្គិសនីដែលអាចទុកចិត្តបាននិងមានតម្លៃថោកដើម្បីផ្គត់ផ្គង់ដល់កំណើនសេដ្ឋកិច្ចកម្ពុជា គឺជាបញ្ហាប្រឈមគន្លឹះមួយដែលរាជរដ្ឋាភិបាលកម្ពុជាជួបប្រទះ។ របាយការណ៍នេះផ្តល់ជាអនុសាសន៍សូមឱ្យប្រទេសកម្ពុជាអនុម័តយកបទពិសោធន៍អន្តរជាតិប្រសើរបំផុតនៅក្នុងការធ្វើផែនការអគ្គិសនី រួមទាំងរបកគំហើញរបស់គណៈកម្មការពិភពលោកស្តីពីទំនប់ (World Commission on Dams) ដែលត្រូវបានគេទទួលស្គាល់យ៉ាងទូលាយថាជាបទដ្ឋានអន្តរជាតិសម្រាប់ការធ្វើផែនការថាមពលនិងទឹក។

លោក **ន័ សាន** អនុប្រធានប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានមានប្រសាសន៍ថា "ប្រទេសកម្ពុជាមានជម្រើសជាច្រើនដើម្បីបំពេញសេចក្តីត្រូវការអគ្គិសនីរបស់យើង រួមទាំងជម្រើសថាមពលកកើតថ្មី និងវិមជ្ឈការផងដែរ ដែលគេត្រូវតែពិនិត្យមើលលទ្ធភាព"។ លោកបានបន្តទៀតថា "យើងកំពុងស្នើសុំឱ្យរាជរដ្ឋាភិបាលបើកឱ្យមានការចូលរួមពីសាធារណៈជននៅក្នុងដំណើរការធ្វើផែនការដើម្បីធានាឱ្យបានប្រាកដថាប្រព័ន្ធអគ្គិសនីកម្ពុជាគឺមានតម្លៃសមរម្យ ប្រកបដោយនិរន្តរភាព និងតភ្ជាប់ជូនប្រជាជនគ្រប់រូប។"

របាយការណ៍នេះអាចរកបានពី www.internationalrivers.org/en/southeast-asia/cambodia និង www.ngoforum.org.kh ។

**ទំនាក់ទំនង:**


- **ខាល មីឌ្ឌលតុន** (Carl Middleton) អ្នកសម្របសម្រួលកម្មវិធីទន្លេមេគង្គ អង្គការទន្លេអន្តរជាតិ (International Rivers)
  (+66 84 681 5332; carl@internationalrivers.org)
- **ន័ សាន** អនុប្រធានប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
  (+855 16 852 552; san@ngoforum.org.kh)